# សំពត់៖ សមុច្ច័យពីភាគតូចៗ
## ដោយ  ចាន់ ដានី

ចាន់ ដានី ត្រូវបានគេស្គាល់តាមរយៈការបកស្រាយថ្មីនូវទម្រង់ និងទម្លាប់វប្បធម៌ខ្មែរ បុរាណដែលរក្សានូវគ្រឹះសោភណភាព និងសីលធម៌ នៅកម្ពុជាសព្វថ្ងៃ។ ទោះបីសម្របតាមក្បួន តែងលម្អបុរាណ ឬតួអង្គទេវកថាក្តី ដានីប្រើចំណេះដឹងពីទម្រង់ដែលប្រើក្បួន និងបច្ចេកទេស ដែលរាប់ពីការគូរផាត់ពណ៌ ទៅដល់ការដេរ និងបិទផ្គុំ ជាមួយរូបធាតុថ្មីៗ។ វិជ្ជាដ៏លំបាក ហើយ ច្រើនតែម៉ត់ចត់របស់គាត់ទាមទារនូវការសមនិងការអត់ធ្មត់ដែលសេសសល់ពីវិធីសាស្រ្តផលិតរបស់ គ្រូសិប្បករបុរាណ។ តែដានី ក៏ក្រសោបយកនូវការផ្លាស់ប្តូរ និងលេងទៅតាមទម្រង់អភិរក្សដែរ។

*សំពត់: សមុច្ច័យពីភាគតូចៗ* ជាឈុតស្នាដៃវាយនភ័ណ្ឌ ដែលដកស្រង់តាមសំពត់ ក្រណាត់រាងចតុកោណកែងដែលទាំងនារី និងបុរសពាក់នៅតំបន់ភាគច្រើននៃអាស៊ីអាគ្នេយ៍។ សាច់ក្រណាត់មានប្រវត្តិបុរាណនិងរស់រវើកនៅកម្ពុជា ហើយរហូតដល់សព្វថ្ងៃត្រូវបានត្បាញ ដោយដៃតាមប្រពៃណី ដោយមានថ្នាំជ្រលក់ធម្មជាតិ និងសូត្រស្តើងសម្រាប់មុខងារវិចិត្រកម្ម និងពិធី និងជាសម្លៀកបំពាក់ប្រចាំថ្ងៃ។ *សំពត់ហូល* ដែលឧស្សាហ៍ប្រើមានលំនាំដែលប្រើក្បួន ជាង ២០០ ដែលប្រែប្រួលតាមតំបន់ គិតតាមខ្សែធរណីមាត្រ ប្រជឹស ផ្កាយ និងអុជរុក្ខជាតិ និងសត្វ។ ទាំងអស់នេះ បែរហាក់ដូចជាមិនតាមក្រមទៅវិញ ពេលលេងលើសំពត់ដែលមិនអាច ស្លៀកបានរបស់ ដានី។

ដំណើរការរបស់ ដានី គឺបញ្ច្រាសនឹងដំណើរការរបស់អ្នកត្បាញ ទោះបីធ្វើដោយដៃក៏ ដោយ  ពុំមានឃើញប្រើកីឬម៉ាស៊ីនអ្វីទេ។ បើយកចិត្តទុកដាក់នឹងក្បាច់លម្អិត គេឃើញច្បាស់ និងអាចមានការចោទសួរ ដោយជំរុញនូវការពិចារណាលើភាពសុក្រឹត្យ និងអសុក្រឹត្យ។ ស្នាម គំនូសឃើញមានខ្សែត្រង់ដូចជាបំពេញមិនបានផ្នែកពេញ និងមិនពេញនៃការប៉ាក់គឺនៅក្បែរគ្នា។ ជាជាងប្រើសូត្រស្តើង ឬអំបោះបោះពុម្ព ដានីធ្វើឱ្យរូបធាតុដែលគេបោះចោលមានប្រយោជន៍ឡើង វិញ ដោយរបស់ទាំងនោះភាគច្រើននាំចូលពីកូរ៉េខាងត្បូង តាមរយៈទីផ្សារជជុះ។ ការជ្រើសរើស រូបធាតុសំយោគ ពណ៌ និងឱនលម្អពីលើអង្កាំ និងពេជ្រចម្លងនេះ ត្រាប់តាមនិន្នាការម៉ូតបច្ចុប្បន្ន របស់ជំនាន់សិល្បករយើង ដោយលេងគំនិតក្នុងការសាងរូបភាព និងភាពគួរឱ្យចង់បាន។

បើតាមសិល្បករយើង វាយនភណ្ឌនីមួយៗត្រូវបានកំណត់ដោយសម្ព័ន្ធភាពរវាងទម្រង់ និងលក្ខណៈពិសេសនៃសមាសធាតុផ្សេងៗ៖ ការដែលគាត់រំលឹកដល់លំនាំ និងរូបភាពដែល ពីដើមត្បាញ ឬបោះពុម្ពលើសាច់*សំពត់* ដែលត្រូវតែងតែឃើញមានក្នុងគ្រួសាររបស់គាត់ ភាព ទាក់ទាញនៃការចម្លងតាមសំណួរនៃសោភណភាព និងចំណេះដឹងរបស់គាត់ និងការកែច្នៃជាប់នូវ *ក្បាច់* ជាក្បួនតែងលម្អខ្មែរបុរាណ។

**អំពីសិល្បករ**

ចាន់ ដានី កើតនៅខេត្ត ព្រៃវែង នៅឆ្នាំ១៩៨៤ ហើយរស់នៅនិងធ្វើការនៅភ្នំពេញ។ ពិព័រណ៌សម្រាំងខ្លះៗរួមមាន បាសែលសិល្បៈហុងកុង នៅវិចិត្រសាល 10 Chancery Lane Gallery ២០១៣, *កម្មសិទ្ធិ* នៅមជ្ឈមណ្ឌលសិល្បៈ និងវប្បធម៌បាងកក ២០១៣, *ស្រកាអង្គរ* នៅសណ្ឋាគារដឺឡាប៉េ ២០១១, *ការតាំងចិត្តថ្មីរបស់អាស៊ី* គម្រោងប៉ាលេវីយែណា ២០០៩, *យុទ្ធសាស្រ្តពីខាងក្នុង* នៅមជ្ឈមណ្ឌលសិល្បៈសហសម័យកឺ សៀងហៃ ២០០៨, *ក្នុងអន្តរកាល* នៅវិទ្យាស្ថានរ៉េយំ ភ្នំពេញ ២០០៧។

# Sampot: The Collection of Small Things
## Chan Dany

Chan Dany is known for reinterpreting ancient Khmer cultural forms and practices that retain aesthetic and moral ground in today's Cambodia. Whether appropriating traditional ornamental codes or mythological characters, Chan employs knowledge of codified forms and techniques ranging from painting to sewing and collage with novel materials. His arduous and often delicate practice requires a repetition and patience reminiscent of traditional master-artisan methods of production, yet Chan embraces change and play as forms of preservation.

*Sampot: The Collection of Small Things* is a series of textile works inspired by the sampot, - the rectangular cloth worn by both women and men throughout much of South and Southeast Asia. The fabrics have an ancient and living history in Cambodia and until today are traditionally hand woven with natural dyes and fine silks and cottons for pictorial and ceremonial function and everyday wear. The common *sampot hol* has over 200 codified patterns, which vary by region in terms of their geometric and organic lines, lattices, stars and dots, flora and fauna motifs  – all of which appear - however uncodified and at play - in Chan's unwearable sampots.

Chan's process contrasts to that of a weaver; although handmade, no loom or machine is employed. Attention to detail is both obvious and questionable, encouraging reflection on perfection and imperfection. Sketch marks are present, straight lines seems unachievable, complete and incomplete sections of embroidery are juxtaposed. Instead of fine silks or printed cotton, Chan reinvigorates discarded materials, many of which have been imported from South Korea via the second hand market chain. This selection of synthetic material, color, and appliqué of sequins, imitation pearls and diamonds mimic current fashion trends of the artists' generation, playing with ideas of constructing image and desirability.

According to the artist, each textile is determined by the relationship between the forms and characteristics of the various components: his homage to the patterns and images originally woven or printed on *sampot* fabrics which have been ever-present in his family, the allure of imitation, the question of beauty, and his knowledge and ongoing reworking of *kbach* – traditional Khmer ornamental codes derived from nature.

**About the Artist**

Chan Dany's was born in Prey Veng, 1984 and lives and works in Phnom Penh. Select exhibitions include Art Basel HK, 10 Chancery Lane Gallery 2013, *Posession*, Bangkok Art and Cultural Center, 2013, *The Scale of Angkor*, Hotel de La Paix Arts Lounge, 2011; *New Asian Promises*, Palais Project, Vienna 2009; *Strategies from Within*, Ke Centre of Contemporary Art, Shanghai 2008, and *In Transition*, Reyum, Phnom Penh, 2007.


+855 (0)17 774 864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សា-សាបាសាក់ SA SA BASSAC

# សំពត់៖ សមុច្ច័យពីភាគតូចៗ
# ដោយ  ចាន់ ដានី

# Sampot: The Collection of Small Things
# Chan Dany

23 May - 28 July 2013



Chan Dany
*Sampot: The Collection of Small Things (More Dok Chan Flowers)*
Lycra, lace, plastic beads, sequins, cotton thread
100 x 150 cm